# នេះជាទីបន្ទាល់ដ៏អស្ចារ្យរបស់ភិក្ខុសង្ឃមួយអង្គនៅប្រទេសភូមា ដែលបានស្លាប់ហើយរស់ឡើងវិញផ្លាស់ប្រែទាំងស្រុង!

## សេចក្តីផ្តើម *Introduction*

រឿងខាងក្រោមនេះគឺជាការបកប្រែចេញពីទីបន្ទាល់មួយតាមខ្សែអាត់ (a taped testimony) អំពីបុរសម្នាក់ដែលមានរឿងដ៏អស្ចារ្យមួយធ្វើឱ្យជីវិតរបស់គាត់ បានផ្លាស់ប្រែទាំងស្រុង ។ រឿងនេះមិនមែនជាបទសម្ភាសន៍ ឬ ជាជីវប្រវត្តិទេ ប៉ុន្តែជាពាក្យពេចន៍ផ្ទាល់របស់បុរសរូបនោះ ។ មនុស្សម្នាមានប្រតិកម្មខុសៗគ្នាពេលគេបានឮរឿងនេះ ។ អ្នកខ្លះមានការប៉ះពាល់ចិត្តជាខ្លាំង អ្នកខ្លះសង្ស័យ ហើយមានមនុស្សតិចតួចសើចចំអកខ្លះ ខឹងក្រេវ ក្រោធដោយគិតថាពាក្យទាំងនេះ គឺជាការរវើរវាយរបស់មនុស្សឆ្កួតម្នាក់ ឬ ជាសេចក្តីបោកបញ្ឆោតមួយយ៉ាងប៉ិនប្រសប់ ប៉ុន្តែមនុស្សមួយចំនួនបានប្រែចិត្ត ហើយទទួលជឿដល់ ព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះរបស់ខ្លួន (to receive Jesus Christ as their personal Lord and Savior) ។

មុនដំបូង យើងបានដឹងរឿងនេះតាមរយៈអ្នកដឹកនាំគ្រិស្តបរិស័ទមួយចំនួន នៅប្រទេសភូមាដែលបានចែកចាយរឿងនេះប្រាប់យើង ពួកអ្នកដឹកនាំទាំងនេះបានស្រាវជ្រាវពីរឿងនេះ ហើយគេបានឃើញថា រឿងនេះមិនមែនជាការប្រឌិតបញ្ឆោត ឬ ជារឿងភូតភរឡើយ ហើយដោយករណីនេះហើយទើបយើងខ្ញុំសំរេចចិត្តថា ត្រូវតែបន្តផ្សព្វផ្សាយរឿងនេះឱ្យមនុស្សគ្រប់គ្នាបានដឹង ។ យើងធ្វើដូច្នេះមិនមែនដើម្បីរឿងលុយកាក ឬ រកកេរ្តិ៍ឈ្មោះឱ្យមនុស្សណាម្នាក់នោះទេគឺយើងគ្រាន់តែចង់ឱ្យរឿងនេះផ្ទាល់ បានសម្តែងប្រាប់ឱ្យមនុស្សលោកដឹង ហើយស្វាគមន៍ដល់អ្នកជឿជាគ្រិស្តបរិស័ទពិចារណាមើលរឿងនេះទៅតាមបទគម្ពីរ (Scripture ឬ Bible)ចុះ ។ ប្រសិនបើព្រះជាម្ចាស់ ចង់ឱ្យផ្នែកណាមួយ នៃរឿងនេះសម្រាប់ជាសិរីរុង រឿងរបស់ព្រះអង្គ ឬ ដើម្បីលើកទឹកចិត្តដល់ប្រជារាស្ត្ររបស់ព្រះអង្គនោះ យើងអធិស្ឋាន សូមឱ្យព្រះវិញ្ញាណព្រះអង្គ ធ្វើការនៅក្នុងចិត្តរបស់អ្នកស្តាប់ ហើយជាមធ្យោបាយមួយ ដើម្បីជួយសង្គ្រោះព្រលឹងមនុស្សឱ្យរួចពី ស្ថាននរក (If God wants any part of it to be intended for His glory or to encourage His people, then we pray His Spirit will work in the hearts of the readers in those ways.) ។

អ្នកខ្លះបានប្រាប់យើងថា ភិក្ខុសង្ឃនៅក្នុងរឿងនេះ គេគិតថាគាត់មិនមែនស្លាប់ទេ គឺគាត់គ្រាន់តែភ្លឹកលែងដឹងខ្លួន ហើយហេតុការណ៍ដែលគាត់បានឃើញ និងបានឮ គឺជាផ្នែកមួយនៃការរវើរវាយដោយសារតែក្តៅខ្លាំងពេក ។ ទោះជាលោកអ្នកគិតយ៉ាងណាក៏ដោយចុះ តែហេតុការណ៍ពិតនៃរឿងនេះ បានផ្លាស់ប្រែបុរសរូបនេះទាំងស្រុង រហូតដល់ជីវិតរបស់គាត់ខុសពីមុន 180អង្សា (180-degree) ។ ក្រោយពីព្រឹត្តិការដែលបានកើតឡើង ដូចបានរៀបរាប់ខាងក្រោម គាត់បានរៀបរាប់រឿងរបស់គាត់ប្រាប់គេដោយក្លាហាន គ្មានខ្លាចរអែងប្រថុយជីវិត នឹងគ្រោះថ្នាក់រាប់ទាំងការជាប់គុកទៀតផង (He has fearlessly and boldly told his story at great personal cost, including imprisonment.) ។ គាត់បានទទួលការប្រមាថមើលងាយ ពីបងប្អូនពីមិត្តភ័ក្តិ ពីមិត្តរួមជំនាន់ ហើយប្រឈរមុខនឹងការគំរាមកំហែង ដល់ជីវិត ដោយព្រោះតែមិនព្រមឈប់ប្រកាសពីបទពិសោធន៍ជីវិតដែលគាត់បានជួបប្រទះ (He has been scorned by his relatives, friends and colleagues, and faced death threats for his unwillingness to compromise his message.) ។ តើការអ្វីដែលជម្រុញឱ្យបុរស នេះសុខចិត្តប្រថុយជីវិតរាល់ឧបសគ្គដូច្នេះ? ទោះជាយើងជឿគាត់ ឬ មិនជឿគាត់ក៏ដោយរឿងរបស់គាត់មនុស្សគ្រប់គ្នាគួរតែស្តាប់ ហើយពិចារណាចុះ ។

## ឆ្នាំដំបូងរបស់ខ្ញុំ *My Early Year*

***ខាងក្រោមនេះជាពាក្យរបស់ភិក្ខុសង្ឃរូបនេះ***

សួស្តី ខ្ញុំឈ្មោះ **Athet Pyan Shinthaw Paulu ( អាត់ថេត ពីយ៉ាន់ ស៊ីនថោ ពូលូ )** ខ្ញុំនៅប្រទេសភូមា (Myanmar មីយ៉ានម៉ា ពីមុនដែលគេហៅថា Burma ប៊័រម៉ា) ខ្ញុំសូមរៀបរាប់ពីទីបន្ទាល់ (testimony) របស់ខ្ញុំប្រាប់លោកអ្នកពីហេតុការណ៍ដែលបានកើតឡើងដល់ខ្ញុំ ប៉ុន្តែជាបឋមខ្ញុំសូមជម្រាបជូនពីសាវតារបស់ខ្ញុំខ្លះៗ ដោយសង្ខេបដូចតទៅ : ខ្ញុំកើតនៅឆ្នាំ 1958 នៅក្រុង Bogale ( បូហ្គេល ) នៅតំបន Irrawaddy Delta ( អ៊ីរ៉ាវ៉ាឌី ដេលតា ) ភាគខាងត្បូងនៃប្រទេសភូមា ។ ឪពុកម្តាយរបស់ខ្ញុំជាពុទ្ធសាសនិកដ៏ស្មោះត្រង់ ដូចជាមនុស្សភាគ ច្រើននៅ ប្រទេសភូមាដែរ ហើយគាត់បានឱ្យឈ្មោះខ្ញុំថា Thitpin ( ធីបពីន ឈ្មោះនេះមានន័យថា ដើមឈើ ) ជីវិតរបស់យើងរស់នៅជា សាមញ្ញធម្មតា ។ ពេលខ្ញុំមានអាយុ 13ឆ្នាំខ្ញុំបានឈប់រៀនហើយចាប់ផ្តើមរកស៊ីជាអ្នកនេសាទត្រីតាមទូក ។ យើងនេសាទបានត្រី ហើយជួនកាលក៏បានបង្គារដែរ នៅតាមទន្លេ និងស្ទឹងមួយចំនួននៅតំបន់ Irrawaddy Delta ( អ៊ីរ៉ាវ៉ាឌី ដេលតា ) ពេលមានអាយុ 16ឆ្នាំខ្ញុំបានក្លាយជាអ្នកដឹកនាំក្រុមនៅក្នុង ទូកនេសាទ ។ នៅពេលនោះខ្ញុំបានរស់នៅក្នុងកោះ Upper Mainmahlagyon ( អាប់ភ័រ ម៉េនម៉ាឡាហ្គីយ៉ន់ ដែលប្រែថា កោះស្រី ស្អាត ) គឺនៅភាគខាងជើងក្រុង Bogale ( បូហ្គេល ) ជាស្រុកកំណើតរបស់ខ្ញុំ ។ ទីកន្លែងនេះនៅប្រហែល 100ម៉ៃល៍ (100 miles = 160 km) នីរតីក្រុង Rangoon ( រ៉ង់ហ្គូន សព្វថ្ងៃនេះហៅថា Yangon យ៉ាំងហ្គូន ) ជារដ្ឋធានីនៃប្រទេសរបស់យើង ។ ថ្ងៃមួយពេលខ្ញុំមានអាយុ 17ឆ្នាំ សំណាញ់របស់យើងជាប់បានត្រីច្រើនមែនទែន ហើយដោយព្រោះតែសប្បាយ នឹងជាប់បានត្រីច្រើនក្រពើមួយធំបានចូលមករកយើងវាបានដេញតាមយើង ហើយព្យាយាមវាយប្រហារមកលើយើង ។ យើងភ័យណាស់ ដូច្នេះយើងក៏ចែវទូកយ៉ាងលឿនទាំងស្លន់ស្លោរសំដៅទៅរកមាត់ច្រាំង ។ ក្រពើនោះបានដេញតាមយើង ហើយបានវាត់កន្ទុយរបស់វាបំបាក់ទូករបស់យើង ។ ទោះជាគ្មាននរណាស្លាប់ នៅ ក្នុងឧប្បត្តិហេតុ នេះក៏ ដោយក៏ការវាយប្រហាររបស់ក្រពើនោះមានឥទ្ធិពលមកលើជីវិតខ្ញុំយ៉ាងខ្លាំង ។ ខ្ញុំលែងចង់រកស៊ីនេសាទត្រីទៀតហើយ ហើយទូកដ៏តូចរបស់យើងបានលិចទៅក្នុងទឹកដោយព្រោះតែក្រពើវាយបំបាក់ ។ យើងត្រូវវិលត្រឡប់ទៅភូមិរបស់យើងវិញនៅយប់នោះតាមទូករត់ឈ្នួល ។

ក្រោយមកមិនយូរប៉ុន្មាន ពួកថៅកែរបស់ឪពុកខ្ញុំបានផ្លាស់ឪពុកខ្ញុំទៅទីក្រុង Rangoon ( រ៉ង់ហ្គូន ) ។ ពេលខ្ញុំមានអាយុ 18ឆ្នាំឪពុកម្តាយខ្ញុំបានបំបួសខ្ញុំជាលោកនេន ។ ឪពុកម្តាយភាគច្រើននៅប្រទេសភូមាតែងព្យាយាមបញ្ជូនកូនឱ្យទៅបួសយ៉ាងហោចណាស់ ក៏រយៈពេលណាមួយដែរដោយគិតថា ការធ្វើដូច្នេះគឺបានសងគុណដល់ឪពុកម្តាយ ។ យើងបានកាន់តាមប្រពៃណី ដូច្នេះអស់រយៈពេលរាប់រយឆ្នាំមកហើយ ។

## សាវ័កព្រះពុទ្ធដ៏ស្វាហាប់ម្នាក់ *A Zealous Disciple of Buddha*

### ***សង្ឃមួយអង្គដែលស្វះស្វែងរកសេចក្តីពិត***

ពេលខ្ញុំចូលដល់អាយុ 19ឆ្នាំ 3ខែ ( នេះនៅឆ្នាំ 1977 ) ខ្ញុំបានក្លាយជាភិក្ខុ ។ ព្រះចៅអធិការនៅវត្តរបស់ខ្ញុំ បានដាក់ឈ្មោះមួយថ្មីដល់ខ្ញុំតាមឈ្មោះព្រះពុទ្ធសាសនា ដែលជាប្រពៃណីនៅក្នុងប្រទេសរបស់យើង ។ ឈ្មោះថ្មីរបស់ខ្ញុំនៅពេលនោះគឺ U Nata Pannita Ashinthuriya ( អ៊ុយណាតា ប៉ាននីតា អាកស៊ីនធូរីយ៉ា ) នៅពេលយើងបួសជាសង្ឃ យើងលែងប្រើឈ្មោះកំណើតដែលឪពុកម្តាយដាក់ឱ្យនោះទៀតហើយ ។ វត្តដែលខ្ញុំបួសនោះ ឈ្មោះ Mandalay Kyaikasan Kyaing ( ម៉ាន់ដាឡេ ខ្យាអ៊ីកាសាន ខ្យាអ៊ីង ) ព្រះចៅអធិការឈ្មោះ U Zadila Kyar Ni Kan Sayadaw ( អ៊ុយហ្សាឌីឡា ខ្យានីកាន់ សៃយ៉ាដោ ) (U Zadila អ៊ុយហ្សាឌីឡា ជាជំណែងរបស់ លោក ) ។ គ្រានោះលោកជាព្រះសង្ឃដ៏ល្បីល្បាញលើសជាងគេទាំងអស់នៅប្រទេសភូមាគ្រប់គ្នាសុទ្ធតែស្គាល់លោក ហើយមនុស្សទាំងអស់ឱ្យតម្លៃនិងគោរពលោកក្នុងឋានៈជាគ្រូធំមួយរូប ។ ខ្ញុំនិយាយដូច្នេះព្រោះនៅឆ្នាំ1983 លោកបានសុគតភ្លាម មួយរំពេចនៅពេលមានគ្រោះថ្នាក់ចរាចរណ៍តាមរថយន្ត ហើយការសុគតរបស់លោកធ្វើឱ្យគ្រប់គ្នាមានការភ្ញាក់ផ្អើលជាខ្លាំង ។ នៅពេលនោះខ្ញុំបួសបាន 6វស្សាហើយ ខ្ញុំបានព្យាយាមធ្វើជាសង្ឃល្អបំផុត ហើយខំប្រឹងប្រតិបត្តិតាមគ្រប់ទាំងធម៌វិន័យ *(precepts)* ទាំងប៉ុន្មាន ដែលព្រះពុទ្ធបានសម្តែងមក ។ ក្នុងដំណាក់កាលមួយ ខ្ញុំបានចូលទៅរស់នៅឯទីស្មសាន (cemetery) មួយដើម្បី

បន្តភាវនាធម៌ ។ ព្រះសង្ឃខ្លះដែលពិតជាចង់ស្គាល់ សេចក្តីពិតរបស់ព្រះពុទ្ធសុទ្ធតែបានធ្វើដូចខ្ញុំ ខ្លះចូលទៅក្នុងព្រៃជ្រៅជាកន្លែងដែលគេរស់នៅជាជីវិតដែលលះបង់ខ្លួនឯងឈប់គិតពីខ្លួនឯង ហើយធ្វើខ្លួនជាក្រតោកយ៉ាក ។ ខ្ញុំបានស្វះស្វែងរកដើម្បីលះបង់គំនិតអាត្មានិយម និងសេចក្តី ប៉ងប្រាថ្នារបស់ខ្ញុំដើម្បីគេចចេញពីកិលេសរោគាព្យាធិ និង ដើម្បីផ្តាច់ចំណងចេញពី វាលវដ្តសង្សារ វិលកើតវិលស្លាប់ របស់លោកិយនេះ (I sought to deny my selfish thoughts and desires, to escape from sickness and suffering and to break free from the cycle of this world.) ។ នៅឯទីស្មសាន ខ្ញុំមិនខ្លាចខ្មោចទេ ខ្ញុំខំព្យាយាមរកឱ្យបានសេចក្តីស្ងប់នៅក្នុងចិត្ត (inner peace) និងការត្រាស់ដឹងដោយខ្លួនឯង(self-realization) ដែលសូម្បីតែនៅពេលមូសទំលើដៃរបស់ខ្ញុំ ខ្ញុំមិនរវល់នឹងបោសវាចេញផង ខ្ញុំទុកឱ្យវាខាំជញ្ជាក់ ឈាមតាមចិត្តចុះ ។

អស់រយះពេលជាច្រើនឆ្នាំ ខ្ញុំបានខំប្រឹងធ្វើជាសង្ឃល្អបំផុត ហើយមិនបានធ្វើបាបដល់សត្វមានជីវិតសោះឡើយ ។ ខ្ញុំបានសិក្សាធម៌វិន័យដែលព្រះពុទ្ធបានបង្រៀន ដូចជាបុព្វបុរស (forefathers)ទាំងអស់របស់ខ្ញុំ ដែលបានឆ្លងកាត់ការទាំងនេះមុនខ្ញុំដែរ ។ ជីវិតរបស់ខ្ញុំបានបន្ត រស់នៅជាសង្ឃបែបនោះរហូតដល់ខ្ញុំបានធ្លាក់ខ្លួនឈឺជាទម្ងន់ ។ ពេលនោះខ្ញុំនៅក្នុងវត្ត Mandalay (ម៉ាន់ដាឡេ) ហើយគេក៏បានយកខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យ ។ ពួកគ្រូពេទ្យបានពិនិត្យមើលជម្ងឺរបស់ខ្ញុំ ហើយប្រាប់ខ្ញុំថា ខ្ញុំមានជម្ងឺគ្រុនលឿងផង គ្រុនចាញ់ផង (I had both *Yellow Fever and malaria at the same time!) ។ បន្ទាប់ពីបានព្យាបាលនៅក្នុង មន្ទីរពេទ្យរយះពេលប្រហែលជា 1ខែមក ជម្ងឺខ្ញុំកាន់តែ ធ្ងន់ឡើង១ ។ ពួកគ្រូពេទ្យបានប្រាប់ខ្ញុំថា ជម្ងឺខ្ញុំគ្មានឱកាស នឹងជាឡើងវិញបានទេ ហើយគេឱ្យខ្ញុំចេញពីមន្ទីរពេទ្យ ដើម្បីត្រៀមរៀបចំសម្រាប់ការស្លាប់វិញ (The doctors told me there was no chance for me to recover and discharged me to make arrangements to die.) ។

(* Yellow Fever fatal infectious disease: an infectious, often fatal viral disease of warm climates, transmitted by mosquitoes and marked by high fever, hemorrhaging, vomiting of blood, liver damage, and jaundice).

នេះជាការពណ៌នាសង្ខេប អំពីអតីតកាលរបស់ខ្ញុំ ហើយបន្ទាប់ទៅនេះ ខ្ញុំសូមជម្រាបជូនលោកអ្នកពីការដ៏អស្ចារ្យខ្លះ១ដែលបានកើតឡើងដល់ខ្ញុំ បន្ទាប់ពីពេលនោះ :

## និមិត្តហេតុអស្ចារ្យមួយដែលបានបំផ្លាស់បំប្រែជីវិតរបស់ខ្ញុំជារៀងរហូត

***A Vision that Changed My Life Forever***

ក្រោយពេលគេឱ្យខ្ញុំចេញពីមន្ទីរពេទ្យ គេបានយកខ្ញុំទៅវត្តវិញ ដើម្បីឱ្យសង្ឃឯទៀត១ បានមើលថែខ្ញុំ ។ ខ្ញុំកាន់តែខ្សោយទៅ១ ហើយក៏ភ្លឹកលែងដឹងខ្លួន ។ ក្រោយមកខ្ញុំបានដឹងថា ខ្ញុំពិតជាបានស្លាប់អស់រយះពេល **3**ថ្ងៃ (I learned later that I actually died for three days.) ។ សាកសពរបស់ខ្ញុំបានរលួយ ធុំខ្លិនស្អុយ ហើយបេះដូងរបស់ខ្ញុំឈប់កម្រើកហើយ ។ សាកសពរបស់ខ្ញុំ ត្រូវបានគេរៀបចំដើម្បីធ្វើពិធីឈាបនកិច្ច (គឺរៀបចំដុត) ហើយមុននឹងដាក់ទៅក្នុងមឈូស គេបានធ្វើពិធីចំអាសទឹក គឺលាងសំអាតសពតាមប្រពៃណីព្រះពុទ្ធសាសនា ។ ទោះជារូបកាយខ្ញុំត្រឡប់ជាសាកសពស្អុយរលួយក៏ដោយតែខ្ញុំចាំថា ព្រលឹងនិងវិញ្ញាណរបស់ខ្ញុំនៅដឹងទាំងអស់ (my mind and spirit were fully alert.) ។ ព្រលឹងរបស់ខ្ញុំកំពុងស្ថិតនៅក្នុងព្យុះសង្ឃរាមួយយ៉ាងខ្លាំង ហើយព្យុះមួយយ៉ាងធំបក់បោកពង្រាបទីនោះទាំងមូល រហូតទាល់តែគ្មានដើមឈើ ឬ រុក្ខជាតិណាមួយអាចនៅជាប់បាន ទីបំផុតក៏ក្លាយទៅជាទីវាលមួយនៅទទេគ្មានអ្វីសោះ ។ ខ្ញុំបានដើរយ៉ាងលឿនកាត់វាលនោះ អស់រយះពេលមួយយ៉ាងយូរ ហើយមិនឃើញមានមនុស្ស នៅទីណាសោះមានតែខ្ញុំម្នាក់ឯង ។ មួយសន្ទុះក្រោយមក ខ្ញុំក៏បានឆ្លងកាត់ស្ទឹងមួយ ។ នៅត្រើយ ម្ខាងនៃស្ទឹងនោះ ខ្ញុំបានឃើញបឹងភ្លើងមួយដ៏គួរឱ្យភ័យខ្លាច (I saw a terrible, terrible lake of fire) និងតក់ស្លុតជាខ្លាំង ។ នៅក្នុងព្រះពុទ្ធសាសនាមិនមានសម្តែងប្រាប់ទីកន្លែងដូច្នេះទេ ។ ជាដំបូងខ្ញុំមានការយល់ច្រឡំ ហើយមិនដឹងថាកន្លែងនោះជាស្ថាននរក (hell)ទេ រហូតដល់ខ្ញុំបានឃើញ YAMA ជាស្តេចនរក (the king of hell) (យ៉ាម៉ានេះ ជាឈ្មោះ ដែលគេបានរៀបរាប់អំពីស្តេចនរក នៅក្នុងវប្បធម៌ជាច្រើននៅបណ្តាប្រទេសអាស៊ី) មុខវាមើលទៅដូចជាមុខសត្វគោ ហើយខ្លួនក៏ដូចជាសត្វគោដែរ ប៉ុន្តែជើងវា ដូចជាជើងសត្វនាគរាជ ។ ក្បាលវាមានស្នែងច្រេងច្រាង មុខវាកាចសាហាវណាស់

ហើយខ្ញុំមានការតក់ស្លុតជាទីបំផុត ។ ខ្ញុំបានសួរវាទាំងភ័យញ័រថា តើលោកឈ្មោះអ្វី? វាឆ្លើយឡើងថា "អញជាស្តេចនរក ជាមេបំផ្លាញ " ("I am the king of hell, the Destroyer.") ។

## បឹងភ្លើងដ៏គួរឱ្យខ្លាចបំផុត *The terrible, terrible lake of fire*

ស្តេចនរក ឬ គេច្រើនហៅថា *មេយមរាជ* បានប្រាប់ខ្ញុំឱ្យមើលទៅក្នុងបឹងភ្លើង ។ ខ្ញុំក៏បានមើលហើយឃើញស្បង់ពណ៌លឿងៗ ដែលព្រះសង្ឃពាក់នៅប្រទេសភូមា ។ លុះខ្ញុំមើលកាន់តែជិត ខ្ញុំឃើញបុរសម្នាក់មានក្បាលកោរសក់ ហើយពេលខ្ញុំមើលទៅមុខបុរសនោះទើបខ្ញុំដឹងថាជាព្រះសង្ឃដ៏ល្បីល្បាញម្នាក់ ដែលបានស្លាប់ដោយគ្រោះថ្នាក់ឡាននៅឆ្នាំ 1983 ឈ្មោះ U Zadila Kyar Ni Kan Sayadaw (អ៊ុយ ហ្សាឌីឡា ខ្យានីកាន់ សៃយ៉ាដោ) ខ្ញុំបានសួរទៅមេយមរាជនោះថា ហេតុអ្វីបានជាសម្តេចព្រះគ្រូចាស់របស់ខ្ញុំ បានជាប់នៅក្នុងបឹងភ្លើងនេះដូច្នេះ? ហេតុអ្វីបានជាលោកនៅក្នុងបឹងភ្លើងនេះ? លោកជាគ្រូម្នាក់ល្អណាស់ លោកបានទេសនានៅក្នុងកាសែ្សតខ្សែអាត់ឈ្មោះ "តើអ្នកជាមនុស្ស ឬ ជាឆ្កែ" ធម៌ទេសនានេះបានជួយមនុស្សរាប់ពាន់នាក់ឱ្យយល់ថា គេជាមនុស្សមានតម្លៃប្រសើរលើសជាងសត្វតិរិច្ឆានឆ្ងាយណាស់ ។ ***ស្តេចនរកបានឆ្លើយថា "មែន គាត់ជាគ្រូម្នាក់ដ៏ល្អប៉ុន្តែគាត់មិនបានជឿដល់ព្រះយេស៊ូគ្រិស្ត ដោយហេតុនេះហើយ បានជាគាត់នៅក្នុងនរកដូច្នេះ" ("Yes, he was a good teacher but he did not believe in Jesus Christ. That's why he is in hell.")*** ។

បន្ទាប់មកខ្ញុំបានទទួលបង្គាប់ឱ្យមើលទៅមនុស្សម្នាក់ទៀត ដែលកំពុងតែនៅក្នុងភ្លើង ។ ខ្ញុំបានឃើញបុរសម្នាក់ មានសក់វែង ចងស្រោបសំយាកចុះមកខាងឆ្វេង លោកក៏ពាក់ស្បង់ចីពរដែរ ។ ខ្ញុំបានសួរមេយមរាជនោះថា "តើនេះជានរណា?" ***មេយមរាជឆ្លើយថា: "នេះគឺជាម្នាក់ដែលឯងថ្វាយបង្គំ ឈ្មោះ Gautama (ហ្គូតាម៉ា គោតមសម្ពុទ្ធ) [Buddha ប៊ូដដា គឺជា ព្រះពុទ្ធ]" ខ្ញុំស្រងាកចិត្តមែនទែន ដោយឃើញ Gautama (គោតមសម្ពុទ្ធ) នៅក្នុងស្ថាននរក*** ។ ខ្ញុំបានប្រកែកតវ៉ាថា "ទេ Gautama (គោតមសម្ពុទ្ធ) ប្រកបដោយធម៌អហឹង្សាមានចរិយាសម្បត្តិល្អត្រឹមត្រូវណាស់ ហេតុអ្វីបានជាលោកកំពុងរងទុក្ខ នៅក្នុងបឹងភ្លើងនេះដូច្នេះ? ***មេយមរាជបានឆ្លើយថា "មិនថាឡើយគាត់ល្អយ៉ាងណាទេ គាត់មកកន្លែងនេះពីព្រោះគាត់មិនបានជឿដល់ ព្រះដែលគង់នៅអស់កល្បជានិច្ច" ("It doesn't matter how good he was. He is in this place because he did not believe in the Eternal God.")*** ។

បន្ទាប់មកខ្ញុំឃើញបុរសម្នាក់ទៀត មើលទៅដូចជាគាត់ស្លៀកពាក់ឯកសណ្ឋានទាហាន គាត់មានរបួសនៅដើមទ្រូងយ៉ាងធំ ខ្ញុំក៏សួរថា "តើបុរសនេះជានរណា?" ***ស្តេចនរកឆ្លើយថា: "នេះគឺជា Aung San (អុងសាន) មេទ័ពបដិវត្តិ ប្រទេសភូមា" ។ ខ្ញុំបានឮសំឡេងប្រាប់ថា "Aung San (អុងសាន) នៅទីនេះ ព្រោះគាត់បានបៀតបៀន ហើយសម្លាប់គ្រិស្តបរិស័ទ ប៉ុន្តែដែលលើសជាងអ្វីទាំងអស់ ដោយព្រោះគាត់មិនបានជឿ ដល់ព្រះយេស៊ូគ្រិស្ត" ("Aung San is here because he persecuted and killed Christians, but mostly because he didn't believe in Jesus Christ.")*** ។ នៅប្រទេសភូមាមានសុភាសិតមួយពោលថា "ទាហានមិនចេះស្លាប់ទេ គេរស់នៅជាអមតៈ "ប៉ុន្តែមានសំឡេងមួយប្រាប់ខ្ញុំថាកងទ័ពស្ថាននរក ក៏មានសុភាសិតមួយដែរពោលថា "ទាហានមិនចេះស្លាប់មែន ប៉ុន្តែគេចុះមក ស្ថាននរកជាអមតៈ" ។

ខ្ញុំមើលទៅហើយឃើញបុរសម្នាក់ទៀតនៅក្នុងបឹងភ្លើង គាត់មានមាឌធំខ្ពស់ ហើយមានពាក់អាវក្រោះ មានកាន់ដាវ និងខែលនៅដៃ ហើយគាត់មានរបួសយ៉ាងជ្រៅនៅថ្ងាស ។ គាត់មានមាឌខ្ពស់ ជាងមនុស្សណាទាំងអស់ មិនដែលឃើញមាននរណាដូចគាត់ឡើយ ពេលគាត់លាតសន្ទឹងដៃរបស់គាត់ ឃើញមានប្រវែង6ហត្ថ និង1ចំអាម ។ ***ស្តេចនរកប្រាប់ថា: "បុរសនេះឈ្មោះ កុលីយ៉ាត (Goliath) វានៅក្នុងស្ថាននរក នេះ ពីព្រោះវាបានប្រមាថមើលងាយ ដល់ព្រះដ៏គង់នៅអស់កល្ប និង ដាវីឌ (David) អ្នកបំរើទ្រង់" ("This man's name is Goliath. He is in hell because he blasphemed the Eternal God and His servant David.")*** ។ ខ្ញុំមិនយល់សោះ ព្រោះខ្ញុំមិនដឹងថា កុលីយ៉ាត (Goliath) ជានរណា? ហើយ ដាវីឌ (David) ជានរណា? ។ មេយមរាជប្រាប់ខ្ញុំថា "កុលីយ៉ាត (Goliath) មានកត់ទុកនៅក្នុងគម្ពីរគ្រិស្តបរិស័ទ *(Christian*

Bible or Holy Bible គម្ពីរបរិសុទ្ធ) អ្នកមិនស្គាល់គាត់ទេនៅពេលនេះ ប៉ុន្តែនៅពេលអ្នកក្លាយទៅជាគ្រិស្តបរិស័ទ (Christian) អ្នកនឹងដឹងថា គាត់ជានរណាហើយ" ។

បន្ទាប់មកខ្ញុំត្រូវបាននាំទៅកន្លែងមួយទៀត នៅទីនោះខ្ញុំឃើញទាំង អ្នកមានទាំងអ្នកក្រកំពុងរៀបចំបរិភោគអាហារល្ងាច ខ្ញុំក៏សួរថា "តើនរណាចំអិនម្ហូបអាហារឱ្យមនុស្សទាំងនេះ?" ***ស្តេចនរកឆ្លើយថា "ពួកអ្នកក្រត្រូវរៀបចំអាហារដោយខ្លួនឯង ប៉ុន្តែពួកអ្នកមាន ឱ្យអ្នកដទៃចំអិនឱ្យ" ។ ពេលអាហារត្រូវបានរៀបចំរួចសម្រាប់ពួកអ្នកមាន គេបានអង្គុយចុះ ដើម្បីបរិភោគ ។ នៅពេលគេចាប់ផ្តើមភ្លាម មានផ្សែងយ៉ាង ក្រាស់ហុយឡើង ។ ពួកអ្នកមានទាំងនោះ គេខំបរិភោគយ៉ាងរហ័សបំផុត ដើម្បីកុំឱ្យឈ្លក់ ពួកគេពិបាកដកដង្ហើមជាខ្លាំងដោយព្រោះតែផ្សែង ពួកគេត្រូវបរិភោគយ៉ាងលឿន ព្រោះគេខ្លាចបាត់លុយ ដ្បិតលុយគឺជា ព្រះរបស់គេ (They had to eat fast because they were fearful of losing their money. Their money is their god.)*** ។

បន្ទាប់មកមានមេយមរាជមួយទៀត បានដើរមករកខ្ញុំហើយខ្ញុំក៏ឃើញសត្វមួយ មានការងារជាអ្នករុញបញ្ចូលភ្លើង ពីក្រោមបឹងភ្លើងនោះ ដើម្បីឱ្យភ្លើងនៅឆេះក្តៅជាប់រហូត ។ សត្វនោះបានសួរខ្ញុំថា "តើអ្នកត្រូវចុះទៅក្នុងបឹងភ្លើងនេះដែរឬ? ខ្ញុំឆ្លើយថា "ទេ ខ្ញុំមកទីនេះគ្រាន់តែសង្កេតមើលប៉ុណ្ណោះ!" អាការៈរបស់សត្វនោះ ដែលកំពុងតែដុតបញ្ចូលភ្លើងគួរឱ្យខ្លាចណាស់ ។ សត្វនោះមានស្នែង10 នៅលើក្បាល ហើយមានលំពែងមួយនៅដៃ ហើយនៅចុងលំពែងនោះ មានផ្លែ7 សុទ្ធតែមុតៗ ។ សត្វនោះប្រាប់ខ្ញុំថាៈ "អ្នកនិយាយត្រូវហើយ គឺអ្នកមកទីនេះគ្រាន់តែសង្កេតមើលប៉ុណ្ណោះ ព្រោះនៅទីនេះខ្ញុំរកឈ្មោះអ្នកមិនឃើញសោះ ដូច្នេះអ្នកមកតាមណាចូរទៅវិញ តាមនោះវិញចុះ" ។ សត្វនោះបានចង្អុល ទៅវាលសោះកក្រោះ ដែលខ្ញុំបានដើរកាត់ពីដំបូងមកមុន ពេលដែលខ្ញុំបានមកដល់បឹងភ្លើងនេះ ។

## ផ្លូវនៃការសម្រេចចិត្ត *The Road of Decision*

ខ្ញុំបានបានដើរយ៉ាងយូររហូតដល់ជើងខ្ញុំចេញឈាម ខ្ញុំឈឺចាប់ហើយក្តៅជាខ្លាំង ។ ទីបំផុតក្រោយពីបានដើរអស់រយៈពេលប្រហែលជា 3 ម៉ោងមក ខ្ញុំបានមកដល់ផ្លូវមួយយ៉ាងធំ ។ ខ្ញុំបានដើរតាមផ្លូវនោះអស់ពេលមួយយូរក្រៃលរហូតដល់បានមកដល់ផ្លូវបំបែកមួយហើយមានផ្លូវមួយបែកទៅខាងឆ្វេងធំណាស់ក៏មានផ្លូវមួយតូច បត់ទៅខាងស្តាំ ។ នៅដើមផ្លូវបំបែកនោះ មានបង្គោលសញ្ញាដាក់ថា ផ្លូវបត់ទៅឆ្វេងគឺសម្រាប់ អស់អ្នកដែលមិនជឿដល់ព្រះអម្ចាស់យេស៊ូគ្រិស្ត (the Lord Jesus Christ) ឯផ្លូវតូចបត់ទៅខាងស្តាំ គឺសម្រាប់អ្នកជឿដល់ព្រះអម្ចាស់យេស៊ូគ្រិស្ត ។

ខ្ញុំមានចិត្តចង់ដឹងថា តើផ្លូវធំទូលាយនោះនាំឆ្ពោះទៅឯណា ដូច្នេះខ្ញុំក៏ដើរទៅតាមផ្លូវនោះសាកមើល ។ ខ្ញុំឃើញមានមនុស្សពីរនាក់កំពុងដើរនៅមុខខ្ញុំ ចំងាយប្រមាណជា 300យ៉ាត (274ម៉ែត្រ) ។ ខ្ញុំខំដើរឱ្យទាន់ ដើម្បីបានដើរជាមួយដែរ ប៉ុន្តែខ្ញុំដើរមិនទាន់គេសោះ ទោះបីជាខ្ញុំខំដើរលឿនយ៉ាងណាក៏ដោយ ដូច្នេះខ្ញុំក៏វិលមកក្រោយមករកផ្លូវបំបែកនោះវិញ ។ ខ្ញុំបន្តតាមមើលបុរសពីរនាក់នោះ ក្នុងកាលដែលគេកំពុងដើរឃ្លាតពីខ្ញុំនៅតាមផ្លូវធំនោះ ។ ពេលអ្នកទាំងពីរបានទៅដល់ចុងផ្លូវនោះ ស្រាប់តែមានគេចាក់សម្លាប់ភ្លាមមួយរំពេច ។ បុរសទាំងនោះបានស្រែកឡើងទាំងឈឺចាប់ជាខ្លាំង ហើយខ្ញុំក៏យំដែរ ពេលខ្ញុំឃើញហេតុការណ៍ដែលបានកើតឡើងដល់ពួកគេ ។ ពេលនោះ ខ្ញុំយល់បានថាផ្លូវដ៏ធំនោះ បញ្ចប់ដោយគ្រោះថ្នាក់យ៉ាងធំ ដល់អស់អ្នកដែលដើរតាមផ្លូវនោះ ។

## ការមើលទៅឯស្ថានសួគ៌ *Looking into Heaven*

ខ្ញុំក៏បានចាប់ផ្តើមដើរតាមផ្លូវតូចជំនួសវិញ គឺជាផ្លូវរបស់អ្នកជឿព្រះយេស៊ូគ្រិស្ត ។ ក្រោយពីធ្វើដំណើរអស់រយៈពេល 1ម៉ោងមកស្រាប់តែផ្ទៃរាបនៅលើផ្លូវនោះ បានប្រែទៅជាមាសសុទ្ធ ។ ផ្លូវមាសនេះជាមាសសុទ្ធល្អណាស់រហូតដល់ឆ្លុះឃើញរូបរបស់ខ្ញុំបានយ៉ាងច្បាស់នៅពេលខ្ញុំឈ្ងោកមុខមកក្រោម ។ បន្ទាប់មកមានបុរសម្នាក់ ស្លៀកពាក់ស (a white robe) ឈរនៅមុខខ្ញុំ ហើយខ្ញុំក៏បានឮគេច្រៀងចម្រៀងពិរោះមែនទែន ពិរោះ

អស្ចារ្យណាស់ បរិសុទ្ធណាស់ពិរោះគ្មានអ្វីប្រៀប! ចម្រៀងនោះពិរោះ ហើយមានន័យលើសជាងចម្រៀង ដែលយើងច្រៀងថ្វាយបង្គំនៅក្នុងព្រះវិហារលើផែនដីនេះទៅទៀត ។ បុរសស្លៀកពាក់សនោះ បានបបួលខ្ញុំឱ្យដើរជាមួយគាត់ ។ ខ្ញុំក៏សួរ តើលោកឈ្មោះអ្វី? ប៉ុន្តែលោកមិនបានឆ្លើយតបខ្ញុំទេ ។ ក្រោយពីខ្ញុំបានសួរឈ្មោះគាត់ 6ដងបុរសនោះក៏ឆ្លើយថា "ខ្ញុំជាអ្នកកាន់កូនសោរស្ថានសួគ៌ (I am the one who holds the key to heaven) ។ ស្ថានសួគ៌គឺជាកន្លែងមួយល្អវិសេសណាស់ (Heaven is a very, very beautiful place) ឥឡូវនេះអ្នកមិនអាចទៅទីនោះបានទេ ប៉ុន្តែបើអ្នកដើរតាមព្រះយេស៊ូគ្រិស្ត អ្នកអាចទៅបាន ក្រោយពីជីវិតរបស់អ្នកបានបញ្ចប់នៅលើផែនដី" ។ បុរសនោះ ឈ្មោះ ពេត្រុស (The man's name was Peter.) ។

បន្ទាប់មកលោកពេត្រុស បានសុំឱ្យខ្ញុំអង្គុយចុះ ហើយគាត់បានបង្ហាញឱ្យខ្ញុំឃើញកន្លែងមួយនៅទិសខាងជើង ។ លោកពេត្រុសមានប្រសាសន៍ថា: "សូមមើលទៅខាងជើង ហើយពិនិត្យមើលព្រះបង្កើតមនុស្សទៅ (Look to the north and see God create man) ។ ខ្ញុំបាន ឃើញព្រះដ៏គង់នៅអស់កល្បពីចម្ងាយ (the Eternal God from a distance) ព្រះមានបន្ទូលទៅកាន់ទេវតា (angel) មួយថា: "ចូរយើងបង្កើតមនុស្ស" ("let us make man.") ។ ទេវតានោះបានអង្វរព្រះថា "សូមកុំបង្កើតមនុស្សមកអី ព្រោះគេនឹងធ្វើខុស ហើយគេនឹងធ្វើឱ្យព្រះអង្គព្រួយ (ក្នុងភាសាភូមា មានន័យត្រង់ថា "គេនឹងធ្វើឱ្យព្រះអង្គបាក់មុខ to make you lose face) ប៉ុន្តែព្រះជាម្ចាស់នៅតែបង្កើតមនុស្សមក ដដែល ។ ព្រះជាម្ចាស់បានផ្លុំខ្យល់ទៅលើមនុស្ស ហើយមនុស្សក៏មានជីវិតរស់ឡើង (God blew on the man and the man came to life.) ព្រះអង្គឱ្យឈ្មោះបុរសនោះមកថា "អ័ដាម" (God gave him the name "Adam".) ***[Adam ប្រែថា "បុរស"]*** ។

## រស់មកវិញមានឈ្មោះថ្មី *Sent Back with a New Name*

បន្ទាប់មកលោកពេត្រុសមានប្រសាសន៍ថា: "បានហើយចូរក្រោកឡើង ហើយត្រឡប់ទៅទីកន្លែងរបស់អ្នកវិញចុះ ***សូមនិយាយប្រាប់មនុស្សដែលថ្វាយបង្គំព្រះពុទ្ធ និងអ្នកដែលថ្វាយបង្គំរូបសំណាកឱ្យគេដឹង សូមប្រាប់គេថា គេនឹងទៅនរកមិនខាន ប្រសិនបើគេមិនព្រមផ្លាស់ប្រែ ។ អស់អ្នកដែលសង់អគារធំៗ សម្រាប់ដាក់រូបសំណាក និងអ្នកដែលធ្វើរូបសំណាក ក៏នឹងត្រូវទៅនរកដែរ ។ អស់អ្នកដែលខំប្រឹងធ្វើបុណ្យសាង កុសលមិនស្គាល់ព្រះ ពួកថ្វាយបង្គំរូបសំណាក ពួកអ្នកដែលអង្គុយស្វឹងស្វាធ ភាវនារកសច្ចធម៌ដោយខ្លួនឯង ខ្លួនទីពឹងខ្លួន ពិសេសគឺចំពោះអស់អ្នកដែលមិនជឿដល់ព្រះយេស៊ូគ្រិស្ត នោះនឹងត្រូវទៅនរកប្រាកដណាស់ (Speak to the people who worship Buddha and who worship idols. Tell them they must go to hell if they don't change. Those who build temples and idols will also have to go to hell. Those who give offerings to the monks to earn merit for themselves with go to hell. All those who pray to the monks and call them 'Pra' [respectful title for monks] will go to hell. Those who chant and 'give life' to idols will go to hell. All those who don't believe in Jesus Christ will go to hell.")*** ។ លោកពេត្រុសប្រាប់ខ្ញុំថា "អ្នកត្រូវតែនិយាយដោយនូវឈ្មោះថ្មីរបស់អ្នកពីពេលនេះតទៅ អ្នកត្រូវបានគេហៅថា **Athet Pyan Shinthaw Paulu** (**អាក់ថេត ពីយ៉ាន់ ស៊ីនថោ ពូលូ**) ***(ជាប៉ូលដែលបានរស់ពីស្លាប់ ឡើងវិញ)*** ។

ខ្ញុំបានតបថា: "ខ្ញុំមិនចង់ត្រឡប់ក្រោយទេ ខ្ញុំចង់ទៅស្ថានសួគ៌" ។ ពួកទេវតាបានបើកបញ្ជីរកមើល ដំបូងពួកលោករកមើលឈ្មោះខ្ញុំកាលពីក្មេងគឺឈ្មោះ Thitpin (ធីបពីន) នៅក្នុងបញ្ជី តែពួកលោករកមិនឃើញសោះ ។ បន្ទាប់មកពួកទេវតាទាំងនោះ រកមើលឈ្មោះខ្ញុំដែលគេបានដាក់ឱ្យកាលខ្ញុំនៅបួសជាសង្ឃគឺ U Nata Pannita Ashinthuriya (អ៊ុយណាតា ប៉ាននីតា អាកស៊ីនធូរីយ៉ា) ប៉ុន្តែក៏គ្មានកត់ទុកនៅក្នុងសៀវភៅនោះដែរ ។ បន្ទាប់មកលោកពេត្រុសបានប្រាប់ខ្ញុំថា "ឈ្មោះអ្នកមិនមានកត់ទុកនៅទីនេះទេ អ្នកត្រូវតែត្រឡប់ទៅវិញ ហើយធ្វើបន្ទាល់អំពីព្រះយេស៊ូប្រាប់ដល់អស់អ្នកដែលមិនជឿ ។

ខ្ញុំបានដើរត្រឡប់មកតាមផ្លូវមាសដដែលនោះវិញ ហើយខ្ញុំបានឮចម្រៀងដ៏ពិរោះម្តងទៀត គឺប្រភេទនៃចម្រៀងដែលខ្ញុំមិនដែលបានឮពីមុនមកសោះ ។ លោកពេត្រុសបានជូនដំណើរខ្ញុំរហូតដល់ពេលដែលខ្ញុំមកដល់ផែនដីវិញ ។ លោកបានបង្ហាញឱ្យខ្ញុំឃើញជណ្តើរមួយ ចុះពីស្ថានសួគ៌

មកដល់ត្រឹមកណ្ដាលអាកាស ជណ្ដើរនោះមិនបានដាក់ចុះដល់ដីទេ គឺនៅឈប់ត្រឹមកណ្ដាលលំហអាកាស ។ នៅលើជណ្ដើរនោះ ខ្ញុំឃើញពួកទេវតាជាច្រើន ខ្លះឡើងទៅស្ថានសួគ៌ ហើយខ្លះទៀតកំពុងចុះតាមជណ្ដើរ ។ ពួកទេវតាទាំងនោះរវល់ណាស់ ខ្ញុំបានសួរលោកពេត្រុសថាៈ "តើទេវតាទាំងនោះជានរណា?" លោកពេត្រុសប្រាប់ថាៈ "ពួកលោកជាអ្នកនាំសាររបស់ព្រះ ពួកលោកកំពុងរាយការណ៍ទៅស្ថានសួគ៌ អំពីឈ្មោះអស់អ្នកដែលបានជឿដល់ព្រះយេស៊ូគ្រិស្ដ និងឈ្មោះរបស់អស់អ្នកដែលមិនជឿ" (Peter answered, "They are messengers of God. They are reporting to heaven the names of all those who believe in Jesus Christ and the names of those who don't believe.") ។ បន្ទាប់មកលោកពេត្រុសប្រាប់ខ្ញុំថាៈ "ឥឡូវនេះដល់ពេលត្រឡប់ទៅវិញហើយ" ។

## តើជាខ្មោចឬ? *It is a ghost?*

ការបន្ទាប់ដែលខ្ញុំបានដឹង គឺជាសំឡេងមនុស្សយំ ។ ខ្ញុំបានឮសំឡេងម្ដាយខ្ញុំស្រែកយំថាៈ "កូនម្ដាយៗ ហេតុអ្វីបានជាកូនទៅចោលម្ដាយ ?" ខ្ញុំក៏ឮសំឡេងមនុស្សជាច្រើនទៀតយំផងដែរ ។ ខ្ញុំដឹងបានថា ខ្ញុំកំពុងដេកនៅក្នុងក្ដារមឈូស ។ ខ្ញុំបានចាប់ផ្ដើមកម្រើក ខ្លួនពេលនោះស្រាប់តែម្ដាយឪពុករបស់ខ្ញុំ ស្រែកឡើងថាៈ "កូនខ្ញុំរស់ហើយ! កូនខ្ញុំរស់ហើយ!" មនុស្សឯទៀតៗដែលនៅឆ្ងាយបន្តិច មិនជឿពាក្យឪពុកម្ដាយរបស់ខ្ញុំទេ ។ បន្ទាប់មកខ្ញុំក៏បោះដៃដាក់លើមាត់ក្ដារមឈូស ហើយក្រោកអង្គុយ ។ មនុស្សជាច្រើនស្រែកស្លន់ស្លោថាៈ " ខ្មោចលងៗ! " ហើយនាំគ្នារត់យ៉ាង លឿនយករួចខ្លួន ។

អ្នកក្រៅពីនោះ ភ័យស្លុតនៅទ្រឹងទៅណាមិនរួច ទាំងឥតនិយាយស្ដី ។ ខ្ញុំបានដឹងខ្លួនថា ខ្ញុំនៅក្នុងសាកសពដែលបានចេញទឹក ហើយមានក្លិនស្អុយ ។ ទឹកស្អុយដក់ក្នុងក្ដាមឈូសនោះប្រហែលជា 3ពែងកន្លះ នេះគឺជាទឹកដែលចេញពីពោះខ្ញុំ និងពីខាងក្នុងខ្លួនខ្ញុំ ពេលដែលសាកសពរបស់ខ្ញុំដេកនៅក្នុងក្ដាមឈូស ។ ដោយព្រោះតែយ៉ាងនេះហើយ មនុស្សម្នាសុទ្ធតែដឹងថា ខ្ញុំបានស្លាប់ពិតមែន ។ នៅព័ទ្ធពីខាងក្នុងមឈូស គេដាក់ក្រដាសផ្លាស្ទិកបិទជាប់ទៅនឹងក្ដារ ដើម្បីកុំឱ្យទឹកដែលចេញពីសាកសពធ្លាយចេញមក ព្រោះជាធម្មតាសាកសព ជាច្រើនតែងតែចេញទឹកដូចជាករណីខ្ញុំនេះដែរ ។

ក្រោយមកខ្ញុំបានដឹងថា ខ្ញុំនៅសល់ពេលតែបន្តិចទៀតប៉ុណ្ណោះ ព្រោះគេបម្រុងនឹងលើកមឈូសសពរបស់ខ្ញុំដាក់ចូលទៅ ក្នុងភ្លើងដើម្បីបូជា ។ រំពេចនោះខ្ញុំក៏បានចាប់ផ្ដើមនិយាយរៀបរាប់ពី ហេតុការណ៍ទាំងប៉ុន្មានដែលខ្ញុំបានឃើញ និងបានឮប្រាប់គេ ហើយមនុស្សម្នាមានការភ្ញាក់ផ្អើលជាខ្លាំង ។ ខ្ញុំបានប្រាប់គេអំពីមនុស្សដែលខ្ញុំបានឃើញនៅក្នុងបឹងភ្លើង (the lake of fire) ហើយប្រាប់គេថាមានតែគ្រិស្ដបរិស័ទទេ ដែលស្គាល់សេចក្ដីពិតនោះ ហើយបុព្វបុរសរបស់យើង ព្រមទាំងយើងរាល់គ្នា មិនបានដឹងពីរឿងនេះ ក៏ឃ្លាតឆ្ងាយពីសេចក្ដីពិ អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ។ ខ្ញុំបានប្រាប់គេថា អ្វីៗទាំងប៉ុន្មានដែលយើងបានជឿកន្លងមកជាសេចក្ដីភូតភរទេ ។ មនុស្សម្នាមានការភ្ញាក់ផ្អើលណាស់ ព្រោះគេគ្រប់គ្នាសុទ្ធតែបានដឹងថា ខ្ញុំជាសង្ឃកាន់តាមធម៌វិន័យដ៏ត្រឹមត្រូវមួយរូប ហើយមានសេចក្ដីឧស្សាហ៍ខ្នះខ្នែងណាស់នៅក្នុងព្រះពុទ្ធសាសនា ។

នៅប្រទេសភូមាពេលមនុស្សស្លាប់គេសរសេរឈ្មោះ និងអាយុរបស់បុគ្គលនោះនៅពីខាងក្ដារមឈូស ។ នៅពេលលោកសង្ឃសុគតទាំងឈ្មោះទាំងអាយុ ហើយនឹងឆ្នាំដែលបានបួសក៏ដូច្នោះដែរ គឺត្រូវបានគេសរសេរដាក់នៅពីខាងក្ដាមឈូស ។ ឈ្មោះខ្ញុំត្រូវបានគេសរសេរជាប់ នឹងក្ដារមឈូស ថាជាមនុស្សស្លាប់រួចទៅហើយ ប៉ុន្តែលោកអ្នកឃើញស្រាប់ ឥឡូវនេះខ្ញុំនៅមានជីវិតរស់ (I had already been recorded as dead but as you can see, now I am alive!) ។

## សេចក្ដីបញ្ចប់ *Epilogue*

ដោយសារលោក Paulu (ពូលូ) ដែលរស់ពីស្លាប់ឡើងវិញ បានជួបប្រទះរឿងរ៉ាវដូចបានរៀបរាប់មកនេះ គាត់បានបន្តធ្វើទីបន្ទាល់ប្រាប់មនុស្សយ៉ាងស្មោះត្រង់ជាប់ជានិច្ច អំពីព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ដ ។ ពួកគ្រូគង្វាលប្រទេសភូមាបានប្រាប់យើងឱ្យដឹងថា គាត់បាននាំព្រះសង្ឃឯទៀត

៧ រាប់រយនាក់ឱ្យទទួលជឿដល់ព្រះយេស៊ូគ្រិស្ត ហើយការធ្វើបន្ទាល់របស់គាត់មានភាពមុតមាំ ហើយដាច់ខាតជានិច្ចឥតសម្រាលឡើយ ។ ដោយព្រោះតែសេចក្តីដែលគាត់ប្រកាសថា **<u>ព្រះអម្ចាស់យេស៊ូគ្រិស្ត ជាផ្លូវតែមួយគត់ទៅស្ថានសួគ៌ គ្មានផ្លូវឯណាទៀតសោះ</u>** បានធ្វើឱ្យមនុស្សជាច្រើនទាស់ចិត្ត ព្រោះគេមិនអាចទទួលយកបាន ។ ទោះបើមានការប្រឆាំងយ៉ាងខ្លាំងក៏ដោយ ក៏ជំនឿរបស់គាត់មិនដែលរង្គើរសោះ ឡើយព្រោះបទពិសោធន៍របស់គាត់ ដែលកើតឡើងដល់គាត់ពិតណាស់ ។ បន្ទាប់ពីបានបួសជាសង្ឃអស់រយៈពេល ជាច្រើនឆ្នាំក្នុងភាពជាអ្នកកាន់តាមធមិ វិន័យរបស់ព្រះពុទ្ធយ៉ាងហ្មឹងម៉ាត់ Paulu (ពូលូ) បានប្រកាសដំណឹងល្អភ្លាម ក្រោយពីគាត់បានរស់ពីស្លាប់ឡើងវិញទាំងបានដាស់តឿនសង្ឃឯទៀត៧ ឱ្យប្រែចិត្តមកទទួលព្រះយេស៊ូគ្រិស្តអស់អំពីចិត្ត ។ មុនពេលគាត់ធ្លាក់ខ្លួនឈឺ រហូតដល់ស្លាប់នោះ Paulu (ពូលូ) មិនដែលស្គាល់អ្វីអំពីជំនឿគ្រិស្តបរិស័ទទាល់តែសោះ ។ ហេតុការទាំងប៉ុន្មាន ដែលគាត់បានរៀនក្នុងរយៈពេល 3 ថ្ងៃនៅក្នុងនរកនោះ គឺជារឿងថ្មីស្រឡាងសម្រាប់គាត ។

ដើម្បីបន្តឱ្យរាជសាររបស់គាត់បានព ដល់មនុស្សជាច្រើនតាមដែលអាចធ្វើទៅបាន <u>ឡាសាជំនាន់ថ្មី (‘modern-day Lazarus’)</u> នេះបានចាប់ផ្តើមចែកផ្សាយ ជាកាសែតខ្សែអាត់សំឡេង ជាវីដេអូរូបភាពដែលនិយាយអំពីរឿងរបស់គាត់នៅក្នុងនោះ ។ ពួកប៉ូលីស និងអាជ្ញាធរធម្មការនៅប្រទេសភូមាបានចាត់វិធានការប្រមូលខ្សែអាតទាំងនោះយកទៅបំផ្លាញចោល ។ ទីបន្ទាល់ដែលលោកអ្នកទើបនឹងបានស្តាប់នេះ បានបកប្រែចេញពីកាស្សែតខ្សែអាត់មួយក្នុងចំណោមកាស្សែតខ្សែអាត់នានារបស់គាត់ ។ មានគេប្រាប់យើងថា សម្រាប់ប្រជាពលរដ្ឋភូមាអ្នកណាមានកាសែតខ្សែអាត់ទាំងនេះ សុទ្ធតែប្រថុយនឹងគ្រោះថ្នាក់ ។

Paulu (ពូលូ) ត្រូវបានគេដាក់គុកម្តង នៅពេលពួកអាជ្ញាធរបំបិទមាត់គាត់មិនបាន ។ កាលបានចេញមកហើយ Paulu (ពូលូ) បានបន្តធ្វើបន្ទាល់ អំពីការទាំងប៉ុន្មានដែលគាត់បានឃើញ និងបានឮឥតឈប់ ។ សព្វថ្ងៃដែលគាត់នៅទីណានោះ គ្មាននរណាដឹងច្បាស់ឡើយ ។ មានជនជាតិភូមាម្នាក់បានប្រាប់យើងថា Paulu (ពូលូ) ជាប់នៅក្នុងគុក ហើយថាអាចត្រូវបានគេសម្លាប់ផងក៏មិនដឹង តែដំណឹងខ្លះទៀតថា ឥឡូវសព្វថ្ងៃនេះ គាត់បានរួចពីគុកហើយ ហើយកំពុងតែបន្តព័ន្ធកិច្ចរបស់គាត់ ។

ប្រសិនបើលោកអ្នកចង់បានពត៌មានពិស្តារបន្ថែម សូមទាក់ទងតាមអាស័យដ្ឋានដូចមានជូនខាងក្រោមៈ

Asian Minorities Outreach
P.O. Box 901
Palestine, Texas 75802
U.S.A.

ឬលោកអ្នកអាចរកមើល ឬ អានជាភាសាអង់គ្លេសនៅក្នុង website: www.bibleprobe.com/backfromthedead.htm

*រូបភាពខាងលើនេះចេញពី www.armo.info/paul.html*

ដើម្បីបានយល់ច្បាស់អំពី អង្គណាជាព្រះពុទ្ធ អង្គណាជាព្រះអាទិករ ឬអាទិទេព សូមអានមើលសៀវភៅវចនានុក្រមខ្មែរ ដែលរៀបរៀងដោយសម្តេចព្រះសង្ឃរាជ ជួនណាត ជោតញ្ញាណោ ទំព័រ 1729 បោះពុម្ពផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ ព.ស 2511 គ.ស 1967 ក្រោមពាក្យថា “**អាទិ** ឬ **អាទិ៍** ” ។

---

# អាក់ថេត ពីយ៉ាន់ ស៊ីនថៅ ពូលូ

## Athet Pyan Shinthaw Paulu

**មានអត្ថបទដូចគ្នានេះក្នុងអសយដ្ឋាន Internet ផ្សេងៗទៀតដូចខាងក្រោម ៖**

***Cambodian*** http://bibleprobe.com/BurmaMonkTestimony-khmer.pdf

***Chinese*** http://bibleprobe.com/back-from-the-dead-chinese.pdf

***English*** http://www.bibleprobe.com/backfromthedead.htm
http://www.jesus.org.uk/dawn/2000/dawn0015.html
http:// www.testimonies.com.au/topics/accidents_1.htm#top
http://www.christian-forum.net/index.php?showtopic=4405
http://www.christian-forum.net/lofiversion/index.php/t4405.html
http://www.hissheep.org/messages/back_from_the_dead_and_budha.html
http://web.archive.org/web/20000510155156/http://www.antioch.com.sg/mission/asianmo/bmonk.html
http://www.mayimhayim.org/Rabbi%20Mike/Remarkable%20Testimony/Back%20from%20the%20dead.htm

***Danish*** (+ Eng) http://udfordringen.com/arkiv/ekstra/buddhistmunk_opstaaet.htm

***Finnish*** http://www.onewaymission.fi/henkilo/burma.php3

***Indonesian*** http://perthindonesianchurch.netfirms.com/Rahib%20Budha.html



General Aung San of Burma – *got killed in 1947*.
http://en.wikipedia.org/wiki/Image:Aung_San.jpg

---

កម្ពុជាសំរាប់ព្រះយេស៊ូ

CambodiaforJesus.com